ជាសង្ខេប

ADB

# ធនាគារអភិវឌ្ឍន៍អាស៊ី និងសង្គមស៊ីវិល

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សហការជាមួយអង្គការសង្គមស៊ីវិលមួយចំនួនធំក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់អាស៊ី -ប៉ាស៊ីហ្វិក ។

ធនាគារអភិវឌ្ឍន៍អាស៊ី（ADB）សហការយ៉ាងទូលំទូលាយ ជាមួយអង្គការសង្គមស៊ីវិល（CSOs）ដោយទទួលស្គាល់ថាអង្គការទាំងនេះគឺជាដៃគូយ៉ាងសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមមុខនៃការអភិវឌ្ឍដ៏ច្រើននៅក្នុងតំបន់ដែលមានប្រជាជនច្រើនបំផុតលើពិភពលោក ។ ADB ទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិលផ្ទាល់ នឹងជួយគាំទ្រការអភិវឌ្ឍសង្គម ដែលជាបង្គោលគ្រឹះមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ ADB ។

ដោយមានការលើកទឹកចិត្តពីប្រជាធិបតេយ្យភាវូបនីយកម្ម និងការរីករាលដាលនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ សង្គមស៊ីវិលបានរីកដុះដាលទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ។ CSOs ដើរតួយ៉ាងសកម្មដល់ការអភិវឌ្ឍក្នុងតំបន់ ហេតុនេះទើបមានការលើកឡើងអំពីទម្រង់ និងការរំពឹងទុកចំពោះតម្លាភាព និងការទទួលខុសត្រូវរបស់អង្គការទាំងនោះ ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ គោលនយោបាយយុទ្ធសាស្ត្រ និងការអនុវត្តរបស់ ADB ត្រូវបានកែតម្រូវ ដើម្បីចាប់យក និងសម្របសម្រួលកិច្ចសហការយ៉ាងសកម្មថែមទៀត ជាមួយ CSOs ចំពោះសកម្មភាពដែលផ្ដល់ហិរញ្ញប្បទានដោយ ADB ។

## សមាសភាពដៃគូ

ADB មានទំនាក់ទំនងជាមួយ CSOs ថ្នាក់ពិភពលោក ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រួមមាន សហជីពកម្មករ អង្គការដែលមានមូលដ្ឋាននៅក្នុងសហគមន៍ មូលនិធិផ្សេងៗ អង្គការមិនមែនរដ្ឋាភិបាលផ្នែកមនុស្សធម៌ និងវិទ្យាស្ថាននានា ដែលធ្វើការងារតស៊ូមតិ ឬ ធ្វើសកម្មភាពចែកចាយសេវានៅក្នុងតំបន់ ដូចជាការងារបរិស្ថាន ជំនួយចំពោះគ្រោះមហន្តរាយ យេនឌ័រ អភិបាលកិច្ច មីក្រូហិរញ្ញវត្ថុ ថាមពល ការផ្គត់ផ្គង់ទឹក និង HIV/AIDS ។

ក្រៅពីកិច្ចសហការថ្នាក់គម្រោង CSOs ក៏បានរួមចំណែកជជែកពិភាក្សាលើគោលនយោ-បាយ និងយុទ្ធសាស្ត្រតាមប្រធានបទ ព្រមទាំងបានជួយរៀបចំយុទ្ធសាស្ត្រដៃគូ តាមប្រទេស（CPSs）ផងដែរ ។

**ADB ទទួលស្គាល់ថាកិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិលផ្ទាល់នឹងជួយគាំទ្រការអភិវឌ្ឍសង្គមដែលជាបង្គោលគ្រឹះមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ ADB ។**

## CSOs ក្នុងកិច្ចប្រតិបត្តិការរបស់ ADB

ជាងបីភាគបួននៃកម្ចីរបស់ ADB បានរួមបញ្ចូលការងារដែលពាក់ព័ន្ធជាមួយ CSOs ។ ការងារទាំងនេះមានចាប់ពីការពិគ្រោះយោបល់ ស្តីពីការការរៀបចំរហូតដល់ការអង្កេតលើសហគមន៍ ការប្រតិបត្តិគម្រោង និងការអង្កេតតាមដាន ។

នៅប្រទេសឥណ្ឌា ADB បាននឹងកំពុងធ្វើការជាមួយអង្គការ ដែលមានមូលដ្ឋាននៅក្នុងសហគមន៍ និង CSOs ជាច្រើន តាមរយៈកម្ចីនៃគម្រោងកែលម្អបរិស្ថាន Kolkata[១] ។ CSOs បានជួយធ្វើសកម្មភាពដែលទាក់ទងនឹងការតាំងទីលំនៅឡើងវិញ ការស្តារតំបន់ជនក្រីក្រ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការចូលរួមរបស់សហគមន៍ ។ អង្គការទាំងនេះក៏បានរួមចំណែកក្នុងការកែលម្អបរិស្ថាន និងការងារអភិវឌ្ឍន៍សហគមន៍នៅក្នុងតំបន់តាំងទីលំនៅ Kolkata ដែលមានប្រាក់ចំណូលទាប ។

កិច្ចសហការរបស់ ADB ជាមួយ CSOs ត្រូវបានសម្របសម្រួលដោយ NGO និងមជ្ឈមណ្ឌលសង្គមស៊ីវិល (NGOC) ដែលមានទីតាំងស្ថិតនៅជាមួយផ្នែកយេនឌ័រ អភិវឌ្ឍសង្គម និងសង្គមស៊ីវិលនៃនាយកដ្ឋានអភិវឌ្ឍន៍តំបន់ និងនិរន្តរភាព ។

NGO ធ្វើការដើម្បីៈ

- ជួយសម្រួលដល់ការធ្វើសមាហរណកម្មនៃចំណេះដឹង និងបទពិសោធន៍របស់ CSOs ទៅក្នុងប្រតិបត្តិការរបស់ ADB ។
- ផ្តល់ព័ត៌មានជាប្រចាំអំពីវិស័យការងារ និងបញ្ហាព្រួយបារម្ភរបស់ CSOs នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ។
- ភ្ជាប់ CSOs ទៅក្នុងកិច្ចពិភាក្សាដែលកំពុងបន្ត និងគ្រប់គ្រងការធ្វើទំនាក់ទំនងជាមួយសង្គមស៊ីវិលទាំងមូលរបស់ ADB ។
- ធ្វើការបង្ហាញ និងកែលម្អសម្ព័ន្ធភាពយុទ្ធសាស្ត្ររវាង ADB និង CSOs ។
- កែលម្អសមត្ថភាពស្ថាប័នរបស់ ADB ដើម្បីសហការប្រកបដោយផ្លែផ្កាជាមួយ CSOs និង
- ផ្តល់ការគាំទ្រ និងការណែនាំដល់មន្ត្រីរបស់ ADB ស្តីពីការពិគ្រោះយោបល់ និងការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងឡាយ ។

គម្រោងដ៏មានឥទ្ធិពលមួយចំនួន ដែលគាំទ្រដោយ ADB ហើយមានការពាក់ព័ន្ធជាមួយ CSOs កំពុងត្រូវបានអនុវត្តតាមរយៈគម្រោងជំនួយបច្ចេកទេសដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់ NGO ក្នុងការរួមចំណែកបញ្ឈប់ និងទប់ស្កាត់ការរីករាលដាលនៃ HIV/AIDS នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលបានផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលស៊ុយអែត[២] ។ ការផ្តល់ជំនួយឥតសំណងខ្នាតតូច កំពុងតែផ្តល់ឱ្យ ADB នូវកាលានុវត្តភាពដើម្បីធ្វើការកាន់តែជិតស្និទ្ធឡើងជាមួយ CSOs ដើម្បីជួយបង្ហាញ រៀបចំឯកសារ និងគាំទ្រសកម្មភាព និងចែកចាយសេវា HIV/AIDS ដល់ជនក្រីក្រ ក្រុមជនងាយរងគ្រោះ និងក្រុមដែលប្រឈមគ្រោះថ្នាក់ខ្ពស់ ។

---

[១] ព័ត៌មានបន្ថែម សូមមើល www.keip.in

[២] សូមមើលអនុគម្រោង លេខ១០ លើ www.adb.org/HIV-AIDS/ta6321.asp

### តួនាទីសំខាន់ៗរបស់ CSOs:

CSOs ផ្តល់តម្លៃបន្ថែមក្នុងការលើកកម្ពស់នូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយដាក់ចេញនូវ :

- **ការកែលម្អ**-កំណត់បង្ហាញនូវវិធីសាស្ត្រ និងគំរូថ្មីសម្រាប់សកម្មភាពអភិវឌ្ឍន៍ជាក់លាក់ដោយទាញយកនូវចំណេះដឹងយ៉ាងច្បាស់អំពីសហគមន៍មូលដ្ឋាន ។
- **ការទទួលខុសត្រូវ**-ជួយធានាថាធាតុផ្សំរបស់គម្រោងត្រូវបានអនុវត្តតាមគិតទុក និងតាមផែនការ ។
- **ការឆ្លើយតប**-លើកទឹកចិត្តការអនុវត្តន៏គម្រោងតាមរបៀបដែលឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន។
- **ការចូលរួម**-ធ្វើជាស្ពានចម្លងរវាងអាជ្ញាធរគម្រោង និងសហគមន៏ដែលទទួលរងផលប៉ះពាល់ និងផ្តល់នូវវេទនាសម្ព័ន្ធសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ។
- **និរន្តរភាព**-រក្សាការបន្តទៅមុខនៃការងារគម្រោង ជាពិសេសនៅពេលដែលទីភ្នាក់ងារអនុវត្តគម្រោងខ្វះសមត្ថភាព ឬពេលមានការផ្លាស់ប្តូរមន្ត្រីបម្រើការ។

ADB បានអនុម័តផ្តល់ជំនួយឥតសំណងដល់ CSOs ចំនួន ១៣ ដែលផ្តល់សេវាការពារ HIV/AIDS នៅប្រទេសអាហ្វហ្គានីស្ថាន បង់ក្លាដែស កម្ពុជា សាធារណរដ្ឋប្រជាមានិតចិន (PRC) កោះហ្វីជី កាហ្សាក់ស្ថាន សាធារណរដ្ឋគីហ្សុី ម៉ុងហ្គោលី ហ្វីលីពីន តាជីគីស្ថាន ថៃ និងវៀតណាម។ នៅសាធារណរដ្ឋប្រជាមានិតចិន លំហូរចេញនៃជនចំណាកស្រុកមួយចំនួនធំពីតំបន់ជនបទ ដើម្បីរកការងារនៅកន្លែងផ្សេងទៀត រួមទាំងការដាក់កំហិតលើការតាំងទីលំនៅឡើងវិញ បានបង្កើតឱ្យមាននូវបាតុភូតក្មេង "ដែលគេទុកចោល" ដែលមិនធ្លាប់មានទាល់តែសោះនៅលើពិភពលោក។ ក្មេងប្រមាណជា ២៣ លាននាក់ ត្រូវបានឳពុកម្តាយទុកចោលដោយការធ្វើចំណាកស្រុក ដើម្បីរកការងារនៅខាងក្រៅដែលជាធម្មតានៅតំបន់ទីក្រុងឆ្ងាយៗ។ នៅក្នុងតំបន់ជនបទក្រីក្រជាច្រើនទៀត ដូចជានៅតំបន់គីងហ្សេននៃខេត្តស៊ីឈួន ក្មេងៗទាំងនេះ មានដល់ទៅជាង ៤0% នៃក្មេងដែលដល់អាយុៈត្រូវចូលសិក្សាទាំងអស់។ មានការទទួលស្គាល់ថា បាតុភូតនេះមានលក្ខណៈអវិជ្ជមានផ្នែកសង្គម។

ជាជំហានមួយដើម្បីដោះស្រាយបញ្ហា ADB បានផ្តល់ជំនួយទៅឱ្យសហព័ន្ធស្ត្រីនៅតំបន់គីងហ្សេន (ជា NGO មួយ) សម្រាប់ជាផ្នែកនៃការសាកល្បងផ្តួចផ្តើមដំបូងលើការអប់រំ និងការថែទាំកុមារនៅក្នុងតំបន់ដែលឳពុកម្តាយបានធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើនៅកន្លែងផ្សេងៗក្នុងប្រទេស[៣]។ កម្រោងសាកល្បងដើម្បីភ្ជាប់ និង ពង្រីកការងាររបស់ ADB ឱ្យបានទូលំទូលាយនៅ PRC ក្នុងការកសាងយន្តការឱ្យទទួលបានជោគជ័យ សម្រាប់ភាពជាដៃគូរវាង NGO និងរដ្ឋាភិបាល។

គម្រោងជំនួយបច្ចេកទេស ដែលគាំទ្រដោយ ADB មួយទៀត ដែលរួមបញ្ចូលការងារពាក់ព័ន្ធជាមួយ CSOs បានជួយរដ្ឋាភិបាល ទីភ្នាក់ងារប្រតិបត្តិគម្រោង និងសហគមន៏នៅប្រទេសស្រីលង្កា និងវៀតណាម ឱ្យសម្រេចបាននូវសេវាផ្គត់ផ្គង់ទឹក និងសេវាអនាម័យ[៤] ប្រកបដោយនិរន្តរភាព និងសមធមិ។ ការផ្តួចផ្តើមគំនិតថ្នាក់តំបន់ បានបង្ហាញនូវគំរូនៃការចូលរួមប្រកបដោយប្រសិទ្ធភាព ដែលកែលម្អ

---

[៣] ព័ត៌មានបន្ថែម សូមមើល www.adb.org/ngos/innovative-partnership.pdf

[៤] ព័ត៌មានបន្ថែម សូមមើល www.adb.org/Documents/ TACRs/REG/38082-REG-TCR.pdf

សមត្ថភាពអ្នកពាក់ព័ន្ធឱ្យចេះរៀបចំ អនុវត្ត និង អង្កេតតាមដានសេវាផ្គត់ផ្គង់ទឹក និងសេវាអនាម័យ ដែលទ្រទ្រង់អ្នកក្រីក្រ ដោយមានការចូលរួម មានវេទយិតភាពយេនឌ័រ និងមានការឆ្លើយតបទៅតាមតម្រូវការ ។

នៅឆ្នាំ ២០០៦ ADB បានបោះពុម្ពផ្សាយនូវសៀវភៅ *មគ្គុទេសន៍បុគ្គលិក ស្តីពីការពិគ្រោះយោបល់ និងការចូលរួម*[៥] ដើម្បីជួយលើកកម្ពស់ និងកែលម្អការអនុវត្តវិធីសាស្ត្រចូលរួមនៅក្នុងប្រតិបត្តិការរបស់ ADB និងដើម្បីពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងឡាយ រួមទាំង CSOs ផង នៅក្នុងសកម្មភាពដែលផ្តល់ជំនួយដោយ ADB ។

## ផែនការការងារស្តីពីកិច្ចសហប្រតិបត្តិការសង្គមស៊ីវិល

កម្មវិធីនៃកិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិលរបស់ ADB ឆ្នាំ ២០០៦-២០០៨ បានបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់ ADB ដើម្បីបន្តធ្វើសមាហរណកម្មចំណេះដឹង និងបទពិសោធន៏របស់សង្គមស៊ីវិលនៅក្នុងប្រតិបត្តិការរបស់ ADB ដោយ ភ្ជាប់ក្រុមសង្គមស៊ីវិលទៅក្នុងកិច្ចពិគ្រោះយោបល់ដែលកំពុងតែដំណើរការអភិវឌ្ឍសម្ព័ន្ធភាពយុទ្ធសាស្ត្រ និងលើកកម្ពស់សមត្ថភាពស្ថាប័នរបស់ ADB ដើម្បីធ្វើការទំនាក់ទំនងយ៉ាងសកម្មថែមទៀតជាមួយសង្គមស៊ីវិល ។

---

[៥] អាចមើល www.adb.org/participation/toolkit-staff-guide.asp


**ព័ត៌មានទំនាក់ទំនង:**

ធនាគារអភិវឌ្ឍន៍អាស៊ី
6 ADB Avenue
Mandaluyong City
1550 Metro Manila
Philippines
Tel +63 2 632 6643
Fax +63 2 636 2409
ngocoordinator@adb.org
www.adb.org/NGOs


ក្នុងការបោះពុម្ពផ្សាយនេះ ដុល្លា មានន័យថា ដុល្លាអាមេរិច